002/19-09-2007-ECCC/TC
E1/92

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 09 / 08 / 2012
ម៉ោង (Time/Heure): 11:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

## សវនាការលើអង្គសេចក្តី - ថ្ងៃទី ៨០

រៀបចំដោយ: ឌុច ផារី និង Andrew James MCINTYRE

| <u>កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ</u> |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Andrew James MCINTYRE, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក ច័ន្ទ តារាស្មី, លោក Tarik ABDULHAK |
| ជនជាប់ចោទ៖ អៀង សារី, នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Andrew IANUZZI, លោក Jasper PAUW |

| |
|---|
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KARNAVAS |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោក Arthur VERCKEN |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក ឡោ ជុនធី, លោក វែន ពៅ, លោក សំ សុគង់, លោកស្រី Beini YE, លោកស្រី Christine MARTINEAU, លោកស្រី ទី ស្រីនណា, លោក Olivier BAHOUGNE |
| អ្នកជំនាញ៖ លោក David CHANDLER |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Simon MEISENBERG, កញ្ញា Julia LEMETAYER, លោកស្រ Robina Struthers, លោក Sheriffo JAMMEH |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២ | ចាប់ផ្តើមម៉ោង៖ ៩.00 | បញ្ចប់ម៉ោង៖ ១៦.00 |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.៣៥ | បញ្ចប់ម៉ោង៖ ១០.៥៥ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១២.00 | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤0 | បញ្ចប់ម៉ោង៖ ១៥.00 |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង និង ៥០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំប្រើឯកសារថ្មី | អង្គជំនុំជម្រះ | ០៩.០៣ | ០៩.០៤ |
| សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលស្នើសុំមិនធ្វើសវនាការនៅថ្ងៃសុក្រ ទី ២០ ខែ កក្កដា ឆ្នាំ ២០១២ | អង្គជំនុំជម្រះ | ០៩.០៤ | ០៩.០៨ |

| | | | |
|---|---|---|---|
| សំណើរបស់មេធាវីការពារក្តី អៀង សារី និងការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់របស់លោក អៀង សារី | មេធាវីការពារក្តី អៀង សារី | ០៩.១០ | ០៩ .២០ |
| ការតាំងសំណួរដល់លោកវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក | អង្គជំនុំជម្រះ | ៩.៣០ | ៩.៣៥ |
| សេចក្តីសម្រេចលើការទំនាក់ទំនងតែម្ខាងជាមួយនឹងអ្នកជំនាញ TCE-11 | អង្គជំនុំជម្រះ | ៩.៤១ | ៩.៤៣ |
| ការតាំងសំណួរដល់អ្នកជំនាញ David Chandler TCE-11 | សហព្រះរាជអាជ្ញា | ០៩.៤៧ | ១៥.៥៧ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្តី នួន ជា | ១២.០៤ | ១២.០៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើការនីតិវិធីសវនាការ ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា ដែលស្នើសុំប្រើឯកសារថ្មី</u>**

អង្គជំនុំជម្រះសម្រេចលើសំណើរបស់មេធាវីការពារក្តី នួន ជា “សំណើលើកទីពីរវិធាន ៨៧ សុំប្រើប្រាស់ឯកសារក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ David Chandler” ឯកសារ E172/27/2 ដែលសំណើនេះស្នើសុំដាក់ឯកសារថ្មីចំនួន១១ នៅចំពោះមុខអង្គជំនុំជម្រះ និងស្នើសុំប្រើប្រាស់ឯកសារនេះនៅពេលតាំងសំណួរដល់អ្នកជំនាញ TCE-11។ អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើ (សូមមើលសេចក្តីសម្រេចខាងក្រោម)។

**<u>សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលស្នើសុំមិនធ្វើសវនាការនៅថ្ងៃសុក្រ ទី ២០ ខែ កក្កដា ឆ្នាំ ២០១២</u>**

អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលបានធ្វើឡើងដោយផ្ទាល់មាត់កាលពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ហើយដែលសំណើនោះបានស្នើសុំមិនឱ្យអង្គជំនុំជម្រះធ្វើសវនាការនៅថ្ងៃ សុក្រ ទី ២០ ខែ កក្កដា ឆ្នាំ២០១២ ព្រោះមេធាវីការពារក្តីអន្តរជាតិរបស់ក្រុមនេះមិនអាចចូលរួមបាន។

**<u>សំណើរបស់មេធាវីការពារក្តី អៀង សារី និងការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់របស់លោក អៀង សារី</u>**

មេធាវីការពារក្តី អៀង សារី ស្នើសុំឲ្យលោកវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក ដែលទទួលបន្ទុកពិនិត្យព្យាបាលលោក អៀង សារី បង្ហាញពីលទ្ធផលនៃការពិនិត្យរបស់គាត់ទាក់ទងនឹងសុខភាពរបស់លោក អៀង សារី ហើយក៏បានបញ្ជាក់ថាលោក អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ផងដែរ។ មេធាវីការពារក្តី អៀង សារី ក៏បានស្នើសុំការណែនាំពីអង្គជំនុំជម្រះផងដែរ ទាក់ទងនឹងការទំនាក់ទំនងរវាងភាគីនិងសាក្សី ពីព្រោះកាលពីថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ មាននូវការទំនាក់ទំនងគ្នាតែម្ខាងរវាងសហព្រះរាជអាជ្ញា និងអ្នកជំនាញ TCE-11 ។ ជាចុងក្រោយ មេធាវីបានស្នើសុំឲ្យមានការបញ្ជាក់ឲ្យបានច្បាស់ផងដែរ តើមានឯកសារអ្វីខ្លះដែលអ្នកជំនាញបានពិនិត្យមុនពេលគាត់មកផ្តល់សក្ខីកម្ម ។

**<u>ការតាំងសំណួរដល់លោកវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក (អំពីសុខភាពរបស់លោក អៀង សារី)</u>**

លោកវេជ្ជបណ្ឌិតរបស់ អ.វ.ត.ក បានបង្ហាញពីការយល់ឃើញរបស់គាត់ទាក់ទងនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ អៀង សារី ។

**<u>សេចក្តីសម្រេចអំពីការទំនាក់ទំនងតែម្ខាងជាមួយនឹងអ្នកជំនាញ TCE-11</u>**

អង្គជំនុំជម្រះបានរំឮកដល់អ្នកជំនាញមិនត្រូវទំនាក់ទំនងជាមួយភាគីណាមួយនោះទេ ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ នួន ជា តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់សម្រាប់ពេលរសៀល។

**<u>ការតាំងសំណួរដល់អ្នកជំនាញ David Chandler (TCE-11)</u>**

សហព្រះរាជអាជ្ញាបន្តការតាំងសំណួរដល់អ្នកជំនាញ TCE-11 ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| N/A | E172/27/1 | 00823757-00823765 00823751-00823756 | សំណើវិធាន ៨៧ សុំប្រើប្រាស់ឯកសារក្នុងអំឡុងពេលសួរដេញដោលអ្នកជំនាញ DAVID Chandler<br>Rule 87 request to use document during cross-examination of expert witness professional DAVID Chandler | P | | | |
| E3/1683 | D108/50/1.75 | 00823678-00823691, 00825418-00825422, 00820987-00820997, 00701668-00701679 00193067-00193488 00824485-00824491, 00825423-00825430, 00726657-00726663 | [Partial T.] ឧបសម្ព័ន្ធ ៧៥៖ សៀវភៅមានចំណងជើងថា សោកនាដកម្មជាប្រវត្តសាស្ត្រនៃប្រទេសកម្ពុជា<br>Annex 75: Book entitled "The Tragedy of Cambodian History"<br>[Partial T.] Annexe 75: Livre de David P. Chandler "The Tragedy of Cambodian History, Politics, War and Revolution since 1945"- Extraits | P | 00820993 | 00193197, 00193299, 00193309, 00193302, 00193309-10, 00193325, 00193084, | |
| E3/17 | D222/1.3 | 00392897-00393174 | [Surrogate Sheet] CHANDLER David, Brother Number One | P | 00821727, 00821739, 00821751, 00821752-3, 00821759, 00821756, 00821762, 00821765, 00821768, 00821666, 00821782, 00821773-74, 00821775 | 00392977-8, 00392988, 00393001, 00393008, 00393005, 00393010, 00393014, 00393016, 00392915, 00393031, 00393021-22, 00393023 | |
| E3/25 | D243/2.1.9 | 00063000-00063058 00491394-00491438 00504014-00504066 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ទង់បដិវត្ត លេខ ពិសេស ធ្នូ-មករា 1976-77<br>[Surrogate Sheet] CPK Magazine entitled: " The Revolutionary Flag", Special Issue, December 1976 –January 1977 (FULL)<br>[Feuille remplacée] CPK Magazine entitled: " The Revolutionary Flag", Special Issue, December 1976 –January 1977 (FULL) | P | 0063039-40 | 00491425 | 00504049-50 |

00832898



| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/1684 | D108/ 50/1.4. 6 | 00191816- 00192089, 00286568- 00286575 00182365- 00182395, 00192667- 00192932 00357247- 00357451 | សៀវភៅនិពន្ធដោយ DAVID Chandler មានចំណងជើងថា៖"សំឡេងពីមន្ទីរ ស-២១"<br>Book by DAVID Chandler entitle: "Voices from S-21 - Terror and History in Pol Pot's Secret Prison"<br>Livre écrit par DAVID Chandler intituté:"Pol Pot, Anatomie d'un cauchemar" | P | 00191853, 00182517- 18, 00191845- 46, | 00192700- 01, 00192815, 00192693- 94 | 00357284-5, 00357395, 00357277 |
| E3/1686 | D366/ 7.1.69 | 00678943- 00679260 00422621- 00422921 00700340- 00700340 | សៀវភៅនិពន្ធដោយ ដេវិឌ ឆាណ្ឌល័រ(David Chandler) មានចំណងជើងថា "ប្រវត្តិសាស្ត្រខ្មែរ"<br>Book by David Chandler entitled "A History of Cambodia" 3rd Edition<br>Livre de David Chandler intitulé "A History of Cambodia" 3em Edition | P | 00679171- 72, 00679175- 77 | 00422838- 9, 00422842 | |
| E3/273 | D262.1 4 | 00657431- 00657462 00167797- 00167863 00725791- 00725804 | [លិខិតបញ្ជាក់ការជំនួសឯកសារ] [កែតម្រូវ១] [Partial T.] ឧបសម្ព័ន្ធ ០០០១៤៖ អៀង សារី រៀបចំពិធីជប់លៀងជូនមន្ត្រីការទូត<br>[Surrogate Sheet] Annex 00014: Foreign Broadcast Information Service collection of reports for January 1976<br>[Feuille remplacée] [Partial T.] Annexe 00014: IENG Sary donne une réception pour les diplomates | P | 00657439- 40 | | 0025796- 97 |
| E3/274 | D262.1 6 | 00700113- 00700122 00167913- 00168005 00700108- 00700112, 00757849- 00757849 | [លិខិតបញ្ជាក់ការជំនួសឯកសារ] [Partial T.] ឧបសម្ព័ន្ធ 00016: សេចក្តីរាយការណ៍អំពីដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រីពាណិជ្ជកម្មនៃសាធារណរដ្ឋប្រជាមានិតចិន<br>[Surrogate Sheet] Annex 00016: Foreign Broadcast Information Service collection of reports for March 1976<br>[Feuille remplacée] [Partial T.] Annexe 00016: Reportage sur la visite du ministre du commerce de la république populaire de chine | P | 00700118 | 00167986 | 00700112 |
| E3/12 | 6.3 | 00003136- 00003142, 00000758- 00000764 00182809- 00182814 00224363- 00224367 | សេចក្តីសំរេចរបស់គណៈមជ្ឈឹមអំពីបញ្ហាផ្សេងៗមួយចំនួន<br>Decision of central committee on a number of problems<br>Decision of central committee on a number of problems | P | 00003140, 00003141 | 00182813, 00182813- 14 | 00224366, 00224366- 67 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/232 | 13.8 | 00017116-00017123<br>00182628-00182634<br>00323932-00323936 | កំណត់ហេតុនៃអង្គប្រជុំការងារប្រចាំថ្ងៃ ៨ មិនា ១៩៧៦<br>Minutes of meeting on local affairs on 8/3/76<br>Minutes of meeting on local affairs on 8/3/76 | P | 00017118 | 00182630 | 00323933 |
| E3/165 | 13.13 | 00053603-00053645<br>00184048-00184078<br>00301334-00301362 | សន្និបាតលើកទី១ សម័យកាលទី ១ របស់សភាតំណាងប្រជាជនម្ពុជា ១១-១៣ មេសា ៧៦<br>General Assemby first session of representative assembly of Kampuchea People 11-13/4/76<br>L'assemblée des représentants du Peuple du Kampuchéa 11-13/4/76 | P | 00053634 | 00184068 | 00301354 |
| E3/197 | 13.9 | 00000744-00000748<br>00182638-00182642<br>00334961-00334963 | កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍រណសិរ្សថ្ងៃទី ១១ មិនា ៧៦<br>Minutes of meeting of permanent committee Front on 11/3/76<br>Procès-verbal de la rénuion du Comité Permanent du Front le 11 mars 1976 | P | 00000744 | 00182638 | 00182638 |
| E3/275 | D262.17 | 00700123-00700145<br>00167594-00167675<br>00685632-00685645 | [លិខិតបញ្ជាក់ការជំនួសឯកសារ] ឧបសម្ព័ន្ធ 00017: លោក ហ៊ូ នឹម (HU Nim) ចេញសេចក្តីប្រកាសព័ត៌មានអំពីសភាតំណាងប្រជាជន<br>[Surrogate Sheet] Annex 00017: Foreign Broadcast Information Service collection of reports for April 1976<br>[Feuille remplacée] Annexe 00017: Hu Nim annonce un communiqué de presse de l'assemblée du peuple | P | | 00167605 | |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- សេចក្តីសំរេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី នួន ជា៖

  អង្គជំនុំជម្រះសម្រេច៖ ឯកសារថ្មីចំនួន ១១ ដែលក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយផ្អែកទៅលើមូលហេតុដូចមានបញ្ជាក់នៅក្នុងសំណើរបស់ខ្លួនដែលបានដាក់ពីពេលមុននោះ(ឯកសារE172/27/1) គឺមិនអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបានទេ ដោយផ្អែកលើមូលហេតុដូចបានបញ្ជាក់នៅក្នុងសេចក្តីសម្រេចផ្ទាល់មាត់របស់ខ្លួនដែលបានប្រកាសនៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១២ ។

- សេចក្តីសំរេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលស្នើសុំមិនធ្វើសវនាការនៅថ្ងៃសុក្រ ទី២០ ខែ កក្កដា ឆ្នាំ ២០១២៖

  អង្គជំនុំជម្រះសម្រេចធ្វើសវនាការនៅថ្ងៃសុក្រ ទី២០ ខែកក្កដា ឆ្នាំ២០១២ ទោះបីជាមានសំណើរបស់មេធាវីការពារក្តី អៀង សារី ដែលស្នើសុំមិនឲ្យអង្គជំនុំជម្រះធ្វើសវនាការនៅថ្ងៃនោះក៏ដោយ។ អង្គ-ជំនុំជម្រះបានរំឭកដល់ភាគីថា ភាគីបានដឹងអំពីពេលវេលាសវនាការតាំងពីពេលចាប់ផ្តើមសវនាការដំបូងមកម្ល៉េះ ដែលថា ទោះបីជាអង្គជំនុំជម្រះមិនធ្វើសវនាការនៅថ្ងៃសុក្រ ក៏ដោយ តែភាគីត្រូវមានភាពបត់បែនលើចំណុចនេះ ព្រោះក្នុងករណីចាំបាច់ អង្គជំនុំជម្រះនឹងធ្វើសវនាការនៅថ្ងៃសុក្រ។វាមានភាពចាំបាច់ដែលអង្គជំនុំជម្រះសម្រេចធ្វើសវនាការនៅថ្ងៃសុក្រ ពីព្រោះអង្គជំនុំជម្រះបានខកខានមិនបានធ្វើសវនាការចំនួនពីរថ្ងៃរួចមកហើយ (ថ្ងៃទី១៦ និង ១៧ ខែកក្កដា ឆ្នាំ២០១២) ដោយសារតែតំណាងសហព្រះរាជអាជ្ញា ដែលទទួលបន្ទុកសម្រាប់សួរដេញដោលអ្នកជំនាញមានជំងឺ ហើយការិយាល័យសហព្រះរាជមិនបានរៀបចំអ្នកជំនួសដើម្បីបន្តនិរន្តរភាពរបស់សវនាការ ។

- អង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យជនជាប់ចោទ អៀង សារី (១០.៣២) និង នួន ជា (១២.០៤) ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការ និងបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់រង់ចាំ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទទាំងពីរ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។

- បង្គាប់ឲ្យនាំអ្នកជំនាញ David Chandler (TCE-11) ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឲ្យនាំគាត់ត្រឡប់មកកាន់សាលសវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២។

- បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទ ត្រឡប់មកកាន់បន្ទប់សវនាការវិញឲ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២។ប្រសិនបើជនជាប់ចោទ អៀង សារី ស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ អង្គជំនុំជម្រះនឹងសម្រេចលើសំណើសុំរបស់គាត់ជាមុន ។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

| សវនាការនឹងបន្តនៅថ្ងៃ សុក្រ ទី ២០ ខែ កក្កដា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។ |
| --- |

ភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារ៉ា** Andrew James MCINTYRE